

IUF៖ បង្រួបបង្រួមកម្មករចំណីអាហារ កសិដ្ឋាន និងសណ្ឋាគារ ជុំវិញពិភពលោក

អាសយដ្ឋាន | 8 Rampe du Pont-Rouge | 1213 Petit-Lancy | Switzerland | IUF@IUF.ORG

# ការទាមទាររបស់ IUF ក្នុងអំឡុងពេលជំងឺកូវីដ១៩៖ វិស័យសណ្ឋាគារ

វិស័យទេសចរណ៍បង្កើតការងារ១០% នៅជុំវិញពិភពលោក ហើយមានស្ត្រីចំនួន ៥៥.៥% នៃកម្លាំងការងារជាសាកលនៅក្នុងវិស័យទេសចរណ៍។ នៅដើមខែមេសា កូវីដ-១៩ បានប៉ះពាល់ដល់ ២០៤ ប្រទេសនិងដែនដី នៅជុំវិញពិភពលោក។ ឧស្សាហកម្មទេសចរណ៍ជុំវិញពិភពលោក បានឈានដល់ចំណុចនឹងថ្កល់ ដោយសារតែការបិទទីក្រុងនិងប្រទេសទាំងមូល។ វិស័យសណ្ឋាគារនិងភោជនីយដ្ឋាន ស្ទើរតែដួលរំលំទៅហើយ។ មានសណ្ឋាគារតិចតួចប៉ុណ្ណោះដែលនៅប្រតិបត្តិ ការ។ ប្រការនេះ បានប៉ះពាល់ជីវភាពរស់នៅរបស់កម្មកររាប់លាននាក់ ដល់គ្រួសាររបស់ពួកគេ និងដល់សហគមន៍ទាំង មូល។

IUF ស្នើឲ្យនិយោជកនិងរដ្ឋាភិបាល មានការប្រុងប្រយ័ត្នថា សិទ្ធិរបស់កម្មករ មិនអាច "ព្យួរ" ឬ "ពន្យារពេល" បានទេ ក្នុងអំឡុងពេលដែលមានព្រឹត្តិការណ៍វិសាមញ្ញទាំងនេះ។ កាតព្វកិច្ចរបស់និយោជក ត្រូវផ្អែកទៅលើអនុសញ្ញា និងឧបករណ៍សិទ្ធិមនុស្សទាំងឡាយ។

ឯកសារនេះ ផ្តល់នូវការទាមទាររបស់សហជីព ដើម្បីការពារកម្មករក្នុងវិស័យសណ្ឋាគារ និងសង្គ្រោះជីវិត ក្នុងការប្រយុទ្ធដើម្បីទប់កុំឲ្យមានការរីកសាយភាពនៃកូវីដ-១៩។

## និយោជក

១. ធ្វើការជាមួយសហជីពដើម្បីអនុវត្តជាបន្ទាន់នូវពិធីសារ ដែលបានរចនាឡើង ដើម្បីជៀសវាងការប្រឈមមុខមិនចាំបាច់នានា ដែលកម្មករត្រូវប្រឈមនឹងហានិភ័យដែលអាចគ្រោះថ្នាក់ដល់សុខភាពពេលបច្ចុប្បន្ននិងពេលអនាគតទៅលើពួកគេ។

២. ផ្តល់ដល់កម្មករនូវព័ត៌មាននិងឧបករណ៍ទបស្កាត់ដែលមានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយ និងចាត់វិធានការបច្ចេកទេសនិងវេជ្ជសាស្ត្រឲ្យបានសមស្រប ឲ្យបានជាបន្ទាន់បំផុតតាមដែលអាចធ្វើបានមុនពេលកម្មករចាប់ផ្តើមវេនធ្វើការរបស់ខ្លួន។

៣. សម្របវេនការងារ ពេលសម្រាក និងផែនការរៀបចំការងារ តាមរបៀបណាមួយដែលអាចទៅរួច ដើម្បីកាត់បន្ថយឲ្យដល់កម្រិតអប្បបរមានៃហានីភ័យ នៅពេលណាដែលចាំបាច់ឲ្យកម្មករបំពេញភារកិច្ច ដែលធានាសេវាសំខាន់ចាំបាច់ ដល់អតិថិជននោះ ត្រូវបានដាប់ឬដាក់ឲ្យនៅដាច់ដោយឡែកនៅក្នុងសណ្ឋាគារ។

៤. ណែនាំអនុវត្តការការពារបន្ថែមសម្រាប់កម្មករដែលអាចមានកត្តាហានិភ័យបន្ថែម ដោយរាប់បញ្ចូលទាំង ការមានផ្ទៃពោះ បុរេលក្ខខណ្ឌវេជ្ជសាស្ត្រ និងជំងឺផ្សេងៗ។

៥. គោរពសិទ្ធិកម្មករ ក្នុងការបដិសេធមិនធ្វើការក្រោមលក្ខខណ្ឌគ្មានសុវត្ថិភាព។

៦. ផ្តល់ការគ្របដណ្តប់ផ្នែកសុខភាពសម្រាប់កម្មករទាំងអស់នៅកន្លែងដែលមិនទាន់មានការធានាជាសាកល ពីប្រព័ន្ធថែទាំសុខភាព។



៧. គោរពសិទ្ធិកម្មករ ក្នុងការធ្វើការរៀបចំជាចាំបាច់ ដើម្បីថែទាំក្រុមគ្រួសាររបស់ពួកគេ។

៨. ធានាការរក្សាប្រាក់ចំណូលរបស់កម្មករនិងការការពារការងារ តាមរយៈវិធានការបណ្តោះអាសន្ន ដែលបានចរចាជាមួយសហជីព។

៩. ទាញប្រយោជន៍ពីអំឡុងពេលនៃការធ្លាក់ចុះដ៏គំហុកនេះ ក្នុងការទាមទារឲ្យមានការបណ្តុះបណ្តាលនិងការផ្លាស់ប្តូរជំនាញ/ការបង្កើនជំនាញរបស់កម្មករ ដើម្បីត្រៀមសម្រាប់ការបន្តសកម្មភាពធុរកិច្ចឡើងវិញ។

១០. អនុម័តគោលនយោបាយស្តីពីការសម្រាកមានប្រាក់កម្រៃនិងការការពារប្រាក់ចំណូល ដែលមានការយល់ដឹងអំពីយេនឌ័រ ដោយសារតែការទទួលខុសត្រូវដែលអសមាមាត្ររបស់ស្ត្រីក្នុងការងារថែទាំកូន។

១១. ផ្តល់ការសម្រាកមានប្រាក់កម្រៃឲ្យបានគ្រប់គ្រាន់ដែលគិតទៅលើការដាក់ខ្លួនដាច់ដោយឡែកនិងការថែទាំសាច់ញាតិមានជំងឺ។

១២. ធានាថារាល់វិធានការទាំងឡាយដែលបានចាត់ឡើង ត្រូវអនុវត្តទៅលើកម្មករទាំងអស់ ដោយរួមទាំង កម្មករក្នុងទម្រង់មិនស្តង់ដាដូចជា អ្នកធ្វើការមិនពេញម៉ោង កម្មករជួលពីក្រៅ កម្មករតាមពេលមានការងារ និងកម្មករក្រៅផ្លូវការ។



## រដ្ឋាភិបាល

១. ទួលស្គាល់ហានិភ័យការងារនិងការលំបាកខ្លាំងក្លាផ្នែកសេដ្ឋកិច្ចដែលកម្មករកំពុងប្រឈម និងណែនាំអនុវត្តវិធានការវិសាមញ្ញសមស្រប ដើម្បីកាត់បន្ថយហានិភ័យទាំងនេះ ដោយសហការគ្នាជាមួយសហជីពនិងនិយោជក។

២. ធានាឲ្យមានសិទ្ធិទទួលបានការសម្រាកពិសេសមានប្រាក់កម្រៃ និងសិទ្ធិទទួលបានការថែទាំសុខភាពដោយមិនគិតកម្រៃ ទោះបីជាទំនាក់ទំនងការងារស្ថិតក្នុងឋានៈបែបណាក៏ដោយ។

៣.និយ័តកម្មទៅលើកម្មករចំណាកស្រុកដែលមិនមានឯកសារគ្រប់គ្រាន់ទាំងអស់ ដើម្បីធានាឲ្យទទួលបានការថែទាំសុខភាព។

៤. ផ្តល់ការសម្រាកឈឺមានប្រាក់កម្រៃឲ្យបានគ្រប់គ្រាន់ ដែលគិតទៅដល់ការដាក់ខ្លួននៅដាច់ដោយឡែកនិងការថែទាំសាច់ញាតិមានជំងឺ។

៥. អនុម័តគោលនយោបាយស្តីពីការសម្រាកមានប្រាក់កម្រៃនិងការការពារប្រាក់ចំណូល ដែលមានការយល់ដឹងអំពីយេនឌ័រ ដោយសារតែការទទួលខុសត្រូវដែលអសមាមាត្ររបស់ស្ត្រីក្នុងការងារថែទាំកូន។

៦.កំណត់ដាច់ខាតអំពីការបណ្តុះបណ្តាលអំពីសុខភាពនិងសុវត្ថិភាព ព្រមទាំងរបៀបប្រើប្រាស់សម្ភារៈការពារខ្លួន។

## ការអនុវត្តល្អបំផុត

សមាជិកបណ្តាញកម្មករចំណីអាហារនៅអាមេរិចខាងជើង UFCW បានធ្វើបច្ចុប្បន្នភាពទំព័រការងាររបស់ខ្លួន ដើម្បីធ្វើឲ្យមានភាពងាយស្រួលសម្រាប់សមាជិកបដិសណ្ឋារកិច្ច UNITE HERE! ក្នុងការស្វែងរកការងារនៅក្នុងវិស័យកែច្នៃចំណីអាហារ ហាងគ្រឿងទេស និងកន្លែងលក់រាយ នៅជួរមុខក្នុងការប្រយុទ្ធដើម្បីធានាសន្តិសុខស្បៀងក្នុងអំឡុងពេលកូវីដ-១៩។ និយោជក កំពុងស្វែងរកបុគ្គលិកសម្រាប់មុខតំណែងទាំងនោះជាប្រញាប់។




សម្រាប់ព័ត៌មានបន្ថែមអំពីភាពជាដៃគូដែលមានលក្ខណៈច្នៃប្រឌិតនេះ សូមមើល www.ufcwjobs.com

## មគ្គុទេសក៍ សម្រាប់ពេលដែលសណ្ឋាគារត្រូវបានគេកាន់កាប់សម្រាប់គោលបំណងផ្សេង

នៅកន្លែងមួយចំនួន គេប្រើប្រាស់សណ្ឋាគារជាទីតាំងសម្រាប់ដាក់មនុស្សដាច់ដោយឡែក និងជាលំនៅដ្ឋានបណ្តោះអាសន្នសម្រាប់មនុស្សកំពុងប្រឈមហានិភ័យខ្ពស់។ កីឡាដ្ឋាន មណ្ឌលសន្និសីទ និងទីតាំងបម្រើសេវាចំណីអាហារផ្សេងទៀត អាចនឹងត្រូវបានគេកាន់កាប់ដើម្បីយកទៅប្រើសម្រាប់ផលិតចំណីអាហារក្នុងស្ថានភាពអាសន្ន ឬជាទីតាំងពិនិត្យអំពីភាពធ្ងន់ធ្ងរនៃជំងឺតាមបែបវេជ្ជសាស្ត្រ។ រដ្ឋាភិបាលកណ្តាលឬរដ្ឋាភិបាលមូលដ្ឋានអាចទទួលបានការអនុញ្ញាតិដោយច្បាប់ពិសេស ដើម្បីរឹបអូសទ្រព្យទាំងនេះសម្រាប់ប្រើក្នុងគោលបំណងទាំងនេះ។ ឬម្យ៉ាងទៀត គេអាចចុះកិច្ចសន្យាជាមួយទីតាំងទាំងនោះ។

### ជំហានទី១៖ ទាក់ទងទៅរដ្ឋាភិបាល

*ទាក់ទងមន្ត្រីរដ្ឋាភិបាល ដើម្បីកំណត់ថាតើពួកគេមានផែនការប្រើប្រាស់ទីតាំងទាំងនោះ យ៉ាងដូចម្តេចខ្លះ*

### ជំហានទី២៖ សំណួរសំខាន់ៗ - រដ្ឋាភិបាល

តើទីភ្នាក់ងាររដ្ឋាភិបាលណា កំពុងមានកិច្ចសន្យាឬកំពុងប្រើប្រាស់អំណាចទាំងនេះ?

តើអ្នកណាកំពុងនៅក្នុងនោះ?

ភារកិច្ចការងារអ្វីខ្លះដែលគេត្រូវការ?

សណ្ឋាគារណា?

អ្នកណាជាអ្នកចំណាយ?

តើអ្នកណាមានសិទ្ធិក្នុងការធ្វើការនៅកន្លែងនោះ?

តើអាជ្ញាធរច្បាប់ស្ថិតនៅក្រោមការប្រតិបត្តិរបស់ ក្រុងណា/តំបន់ណា/រដ្ឋណា?

តើរដ្ឋាភិបាលកំពុងធ្វើដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត (ឧទា. ជួលសណ្ឋាគារទាំងមូល) ឬកំពុងកាន់កាប់ក្រោមច្បាប់គ្រាអាសន្នសាធារណៈ? ក្នុងករណីគ្រាអាសន្ន តើច្បាប់ឬក្រឹត្យសម្រាប់ប្រតិបត្តិចែងដូចម្តេចខ្លះអំពីបុគ្គលិក?

### ជំហានទី៣៖ ការទាមទារសំខាន់ៗ - និយោជកនិងរដ្ឋាភិបាល

- អាជ្ញាធរគួរដាក់បុគ្គលិកនៅទីតាំងនោះ តាមរយៈការជួល ឬកិច្ចសន្យាបន្តជាមួយនិយោជក
- សមាជិកសហជីពទាំងអស់ គួរអាចធ្វើការបានតាមការស្ម័គ្រចិត្ត ប៉ុន្តែបានប្រាក់កម្រៃ
- ប្រសិនបើអ្នកស្ម័គ្រចិត្តមានចំនួនមិនគ្រប់គ្រាន់ទេនោះ ការងារនេះគួរទៅដល់កម្មករផ្នែកបដិសណ្ឋារកិច្ចរបស់សហជីពផ្សេងទៀត
- សុខភាពនិងសុវត្ថិភាព មិនត្រូវបញ្ចុះស្តង់ដារនោះទេ
- គួរមានកន្លែងចតយានជំនិះ ហើយមិនគួរលើកទឹកចិត្តឲ្យប្រើប្រាស់ការដឹកជញ្ជូនសាធារណៈទេ។